## *ការរៀបចំគម្រោងសម្រាប់បណ្តើមគំនិតផ្នែកឧត្តមភាព និង សមធម៌ 2020-2021*

| បណ្តើមគំនិតសម្រាប់សមធម៌ | គោលដៅ | ដឹកនាំដោយ | **2020-2021**<br>*តើលទ្ធផលជោគជ័យមានលក្ខណៈដូចម្តេចក្នុងឆ្នាំនេះ?* |
|---|---|---|---|
| **សម្លេង និង ការរួមចំណែពីសិស្ស**<br>ចំណែកនៃគោលដៅ: 1, 2, 3, & 4<br>(ទាំងអស់នេះជាគោលដៅនៃអគ្គនាយកសាលារៀន) | គោលដៅនៃសម្លេង និង ការរួមចំណែកពីសិស្ស គឺរាប់បញ្ចូលយ៉ាងសកម្មអំពីសម្លេងនៃសិស្សក្នុងការចាត់ចែងសម្រេចមកលើអ្វីទាក់ទងបទពិសោធរបស់ពួកគេនៅក្នុងបន្ទប់រៀន និង សាលារៀន ការរៀបចំមេរៀនបង្ហាត់ស្របតាមការស្ទង់វាស់មតិ ក្រុមចំណែកនៃសិស្ស និង ការវិភាគនៃតំណាងជាសិស្ស ។ | ការិយាល័យនៃឧបអគ្គនាយកសាលារៀន | • ប្រព្រឹត្តតាមកិច្ចការមកពីក្រុមដឹកនាំផ្នែកសមធម៌នៃសិស្ស<br>• ប្រព្រឹត្តតាម បួន ចំណែក នៃ “កិច្ចប្រជុំពិសេស” ជាបន្តបន្ទាប់<br>• វាយផ្សាយដំណឹងតាម វិដេអូ ទៅកាន់សិស្សសម្រាប់បង្ហាញសេចក្តីគាំទ្រមកលើកិច្ចការជាឧត្តមភាព និង សមធម៌ក្នុងក្រសួងអប់រំ ឌីស្ទ្រីគ របស់យើង<br>• បង្កើតទំនាក់ទំនងជាមួយសិស្សតាមរយៈជួបជុំជាក្រុមនៅតាមសាលារៀន និង កិច្ចការដឹកនាំដោយសិស្ស |
| **ការត្រួតមើល និង ជំនួយសម្រាប់នាយកសាលារៀន**<br>ចំណែកនៃគោលដៅ: 1, 2, 3, & 4 | គោលដៅនៃការត្រួតមើល និង ជំនួយសម្រាប់នាយកសាលារៀន គឺបណ្តុះបណ្តាលនាយកសាលារៀនអោយមានជាចំណេះគ្រប់គ្រាន់ និង ទាមទារអោយពួកគេធ្វើការទទួលខុសត្រូវមកលើលទ្ធផលជោគជ័យសម្រាប់សិស្សទាំងអស់ ។ | ការិយាល័យនៃអគ្គនាយកសាលារៀន | • ការធ្វើស្ទង់វាស់មកលើសមត្ថភាពខ្លួនឯងសម្រាប់នាយក និង អនុនាយកសាលារៀន ស្របតាមវិស័យ និង ទំហំកែសម្រួលនៃកម្រិតសម្រាប់ភាពលូតលាស់ជាបន្ត<br>• ការធ្វើស្ទង់វាស់សមត្ថភាពមកលើនាយក និង អនុនាយកសាលារៀន ដោយអ្នកគ្រប់គ្រងពីថ្នាក់លើរបស់ពួកគេ ស្របតាមវិស័យ និង ទំហំកែសម្រួលនៃកម្រិតសម្រាប់ភាពលូតលាស់ជាបន្ត<br>• ចំណេះយល់ដឹងអំពីទំនាក់ទំនងផ្នែកវប្បធម៌ និង ចម្លើយដោះស្រាយនៅតាមបន្ទប់រៀនដោយនាយក និង អនុនាយកសាលារៀន<br>• ការបង្ហាញសមត្ថភាពដោយនាយក និង អនុនាយកសាលារៀនមកលើភាពលូតលាស់នៅតាមសាលារៀនរបស់ពួកគេ ស្របតាមគម្រោងកិច្ចការបង្ហាញជាសមធម៌សម្រាប់ការត្រួតមើល |
| **ជំនួយអប់រំផ្នែកអារម្មណ៍ និង ផ្លូវចិត្ត**<br>ចំណែកនៃគោលដៅ: 1, 2, 3, & 4 | គោលដៅនៃជំនួយអប់រំផ្នែកអារម្មណ៍ និង ផ្លូវចិត្ត គឺបង្កើនការយល់ដឹង វែកញែកមើលអំពីអំពើប្រកាន់ បង្កើតជាទំនាក់ទំនងផ្នែកវប្បធម៌ និង បង្កើនឱកាសកាន់តែច្រើនសម្រាប់មនុស្សធំ និង សិស្សបំពេញកិច្ចការរួមគ្នា ដើម្បីបង្កើតសហគមន៍សាលារៀនជាភាពចម្រុះ ។ | ការិយាល័យផ្តល់ជំនួយទូទៅសម្រាប់សិស្ស | • ការបង្កើតជាចំណេះសម្រាប់គ្រូបង្រៀន និង នាយកគ្រប់គ្រងបំពេញកិច្ចការរួមគ្នា ដើម្បីនាំមកជាលទ្ធផលល្អជាជំនួយអប់រំផ្នែកអារម្មណ៍ និង ផ្លូវចិត្តទៅកាន់សិស្សតាមរយៈកម្មវិធីហ្វឹកហ្វឺនត្រឹមត្រូវ<br>• បណ្តើមគំនិតមកលើការប្រើបន្តជាជំនួយរាប់បញ្ចូលគ្នាសម្រាប់គាំទ្រទៅកាន់ការប្រើវិន័យអប់រំជាកម្រិតថ្នាក់ Tier I-III  ការបង្កើតប្រើជាអំពើយុត្តិធម៌ឡើងវិញ និង ការបណ្តុះភាពទទួលស្គាល់មកលើអត្តសញ្ញាណ<br>• រាប់បញ្ចូលគោលដៅនៃការអប់រំផ្នែកអារម្មណ៍ និង ផ្លូវចិត្តទៅជាមួយមេរៀនដ៏សំខាន់សម្រាប់ការជ្រើសរើសរៀនជាមួយ និង ការបង្ហាត់<br>• បង្កើត និង ប្រើការចែកផ្តល់ជាជំនួយអប់រំផ្នែកអារម្មណ៍ និង ផ្លូវចិត្តទៅកាន់មនុស្សធំ |
| **ទំនាក់ទំនងជាមួយសហគមន៍**<br>ចំណែកនៃគោលដៅ: 1, 2, & 5 | គោលដៅនៃទំនាក់ទំនងជាមួយសហគមន៍ គឺបណ្តុះ និង កសាងជាជំនឿទុកចិត្តជាមួយក្រុមរួមចំណែកទាំងអស់ បង្កើតជាប្រព័ន្ធសម្រាប់ផ្តល់ឱកាសទទួលមតិជាច្រើនមកវិញ ដើម្បីវាយផ្សាយ និង បង្កើនមធ្យោបាយកាន់តែប្រសើរសម្រាប់ក្រសួងអប់រំ ឌីស្ទ្រីគ ធ្វើទំនាក់ទំនងជាមួយមាតាបិតា ។ | ការិយាល័យសមធម៌ និង ទំនាក់ទំនង | • គាំទ្រមកលើការបង្កើត និង ការទទួលស្គាល់កិច្ចការទាក់ទង គម្រោងសម្រាប់ការរៀនបន្ត និង វត្តមានប្រចាំថ្ងៃ និង គម្រោងគ្រប់គ្រង និង ទទួលបន្ទុកប្រចាំតំបន់ តាមរយៈផ្តល់ជាដំណើរការផ្នែករួមចំណែក<br>• បង្កើត និង គាំទ្រមកលើកិច្ចការនៃ ក្រុមដឹកនាំផ្នែកសមធម៌<br>• ទាក់ទាញការរួមចំណែកពីក្រុមរួមចំណែកទាំងអស់ក្នុងដំណើរការពិគ្រោះអំពីថវិកា<br>• រក្សាទុកអំពីលទ្ធផលទាក់ទងការរួមចំណែកជាមួយសហគមន៍ ការទទួលជាមតិ និង អនុសាសន៍ផ្សេងៗមកវិញ<br>• ការផ្តល់ជាកម្មវិធីចាក់បង្ហាញជាច្រើនលើកដោយការិយាល័យ Parent University ដែលសមស្របបណ្តើមគំនិតសំខាន់ៗដូចបានរៀបរាប់មកនៅក្នុងសំណុំរឿងនេះ ដូចជា: កម្មវិធីហ្វឹកហ្វឺនអំពី Canvas និង ការផ្តល់ជំនួយអប់រំផ្នែកអារម្មណ៍ និង ផ្លូវចិត្តទៅកាន់ក្រុមគ្រួសារ ជាដើម |
| **ការបណ្តុះបណ្តាលកម្មវិធី និង ការហ្វឹកហ្វឺន**<br>ចំណែកនៃគោលដៅ: 1, 2, 3, & 4 | គោលដៅនៃកម្មវិធី និង ការហ្វឹកហ្វឺនបណ្តុះបណ្តាល គឺគាំទ្រទៅកាន់គ្រូបង្រៀន និង នាយកដឹកនាំអំពីការបង្កើតសមត្ថភាពជាប្រាំបី ចំណែកសម្រាប់ដោះស្រាយទៅលើការបង្ហាត់ទាក់ទងផ្នែកវប្បធម៌ និង ការរៀបចំកម្មវិធីទាក់ទងស្របវប្បធម៌ ។ | ការិយាល័យ កម្មវិធី ការបង្ហាត់ និង ការហ្វឹកហ្វឺន | • បញ្ជាក់មើលអំពីមធ្យោបាយដូចម្តេចសម្រាប់ឆ្លើយដោះស្រាយទៅកាន់បន្ទប់រៀន ដែលមានទំនាក់ទំនងជាមួយវប្បធម៌<br>• បង្កើតជាចំណែកអនុសាសន៍សម្រាប់កែប្រែមកលើកម្មវិធី ស្របតាមការឆែកពិនិត្យពីក្រសួងអប់រំ ឌីស្ទ្រីគ<br>• ការបង្កើតជាគម្រោង និង ការបញ្ចេញប្រើគម្រោង ដែលរាប់បញ្ចូលទាំងកម្មវិធីហ្វឹកហ្វឺនសម្រាប់នាយកសាលារៀន និង គ្រូបង្រៀនទាក់ទងផ្នែកវប្បធម៌ និង រក្សាការអនុវត្តផ្សេងៗសម្រាប់សង្កត់មកលើលទ្ធផលជោគជ័យផ្នែកសិក្សា សមត្ថភាពយល់ដឹងផ្នែកវប្បធម៌ និង ការយកចិត្តទុកដាក់ដ៏សំខាន់មកលើទំនាក់ទំនងផ្នែកអារម្មណ៍ និង ផ្លូវចិត្ត រួមទាំងសុខុមាលភាពនៃសិស្សផង |
| **ការដឹកនាំផ្នែកសមធម៌ និង បណ្តុះបណ្តាលប្រាជ្ញា**<br>ចំណែកនៃគោលដៅ: 2, 3, & 5 | គោលដៅនៃការដឹកនាំផ្នែកសមធម៌ និង បណ្តុះបណ្តាលប្រាជ្ញា គឺគាំទ្រទៅកាន់គ្រូបង្រៀន និង នាយកសាលារៀនអំពីផ្នែកលូតលាស់ជា 7 វិស័យ និង 21 ទំហំជាខ្នាតគំរូនៃនាយកគ្រប់គ្រងរបស់យើង ។ | ការិយាល័យដឹកនាំផ្នែកសមធម៌ និង បណ្តុះបណ្តាលប្រាជ្ញា | • ការពង្រីក និង ប្រើតាមកម្មវិធីវាយផ្សាយជា 14 ចំណែកពីគ្រូដឹកនាំតាមរយៈជាមួយនាយកគ្រប់គ្រងថ្មី<br>• ការបង្កើតជាកម្មវិធីសង្កត់មកលើសមធម៌សម្រាប់កម្មវិធីវាយផ្សាយនិមួយៗ<br>• យកចិត្តទុកដាក់មកលើការប្រឹងប្រែងសម្រាប់ទាក់ទាញចំណែកជាមួយផ្នែកសមធម៌ និង ការរក្សាទុក ដូចជា: ក្រដាសដាក់ពាក្យ សំនួរ និង កិច្ចការសរសេរ ជាដើម<br>• ការបង្កើនជាដៃគូជាមួយអង្គការនានានៅតាមសហគមន៍សម្រាប់ផ្តល់ជាជំនួយគាំទ្រមកលើកម្មវិធីវាយផ្សាយអំពីសមធម៌ប្រចាំក្រសួងអប់រំ LBUSD |
| **ទំនាក់ទំនងផ្នែកថវិកា**<br>ចំណែកនៃគោលដៅ: 1 & 5 | គោលដៅនៃទំនាក់ទំនងផ្នែកថវិកា គឺទទួលជាយោបល់មកវិញអំពីថវិកាតាមរយៈការរួមចំណែកពីសហគមន៍ ដែលបញ្ជាក់អំពី | ក្រសួងហិរញ្ញវត្ថុ | • បង្កើតការពិគ្រោះជាមួយសហគមន៍អំពីកិច្ចការសំខាន់ៗមុនគេ ដែលត្រូវដោះស្រាយតាមរយៈប្រើថវិកា<br>• ការបង្កើតចំណេះជាមូលដ្ឋានគ្រិះអំពីរបៀបប្រើថវិកាជាមួយសហគមន៍ ដើម្បីទទួលយកជាយោបល់មកវិញ |

| | | | |
|---|---|---|---|
| | ការឆ្លុះបង្ហាញមកលើការប្រើប្រាស់ថវិកាសម្រាប់សមធម៌ និង ធ្វើការដោះស្រាយតាមសេចក្តីត្រូវការនៃក្រសួងអប់រំ ឌីស្រ្ទីគ ។ | | • ការបង្កើតជាឱកាសសម្រាប់បំពេញកិច្ចការរួមជាមួយក្រសួងផ្សេងៗ ដែលទាក់ទងមកលើចំនួនសិស្សចុះឈ្មោះចូលរៀន ចំនួនបុគ្គលិក និង ការចែកផ្តល់ជាជំនួយផ្សេងៗទៅតាមសាលារៀន<br>• បង្កើតជាគម្រោងសម្រាប់ប្រើជាច្រើនឆ្នាំទៅមុខបានជាមួយជំនួយបន្ថែមផ្សេងៗ ដែលប៉ះពាល់មកលើអ្វីត្រូវគិតគូរដោះស្រាយមុនគេសព្វថ្ងៃនេះ |
| **ការអនុវត្តធនធានមនុស្ស និង កម្លាំងការងារជាប្រភពចម្រុះ**<br>ចំណែកនៃគោលដៅ: 2 & 3 | គោលដៅនៃការអនុវត្តធនធានមនុស្ស និង កម្លាំងការងារជាប្រភពចម្រុះ គឺបង្កើតជាការជម្រើសយកថ្មីដែជាកម្រិតខ្ពស់យ៉ាងចម្រុះ ដើម្បីទាក់ទាញ និង រក្សាទុកបុគ្គលិកសម្រាប់បំពេញមុខងារអោយសមស្របតាមសិស្ស និង សហគមន៍របស់យើង ។ រក្សាទុក និង បង្កើនចំនួនបេក្ខជនជាគ្រូបង្រៀន ដែលមានសមត្ថភាពខ្ពស់ផ្នែកបង្ហាត់ថ្នាក់ K-12 អោយឡើងដល់ 10% សម្រាប់ក្រុមសិស្សមានសម្លេងតិច និង ការបង្កើនជាសមធម៌ និង ឧត្តមភាពសម្រាប់គោលដៅនៃក្រសួង ដោយនៅពេលជាមួយគ្នា គឺបង្កើតឱកាសសម្រាប់បង្កើនទំនាក់ទំនងជាមួយបុគ្គលិក និង រក្សាទុកពួកគេអោយនៅតែបំពេញមុខងារក្នុងកន្លែងដដែល ។ | ការិយាល័យ ធនធានមនុស្ស | • ការរែកញែកមើលអំពីរបៀបជួលបុគ្គលិក ការផ្តល់ពិន្ទុមកលើផ្នែកសម្ភាស ការស្ទង់មើលអំពីលទ្ធផលពីការជួលបុគ្គលិកថ្មីៗ និង ការបង្កើតជារបាយការណ៍ប្រចាំឆ្នាំសម្រាប់ស្ទង់វាស់ និង បង្ហាញភាពលូតលាស់អំពីលទ្ធផលជួលបុគ្គលិកចម្រុះ រួមទាំងរបាយការណ៍អំពីកន្លែងអាចស្វែងរកឃើញបានផង<br>• បង្កើតដៃគូជាមួយអនុមហាវិទ្យាល័យ និង វិជ្ជាស្ថានជាកម្រិតកាន់តែខ្ពស់ផ្សេងៗ ដើម្បីធ្វើការវាយផ្សាយអំពីសេចក្តីត្រូវការកាន់តែច្រើនសម្រាប់កម្មវិធីជួយបម្រុងគ្រូបង្រៀនសម្រាប់ទាក់ទាញយកមកបំពេញកិច្ចការបង្ហាត់យ៉ាងចម្រុះទៅអនាគតកាល<br>• បន្តកម្មវិធីហ្វឹកហ្វឺនអំពីការប្រឆាំងអំពើប្រកាន់ពូជសាសន៍ និង អំពើប្រកាន់ផ្សេងៗ<br>• បង្កើតការចុះ កុងត្រា ជាមួយគ្រូ ដែលទើបចាប់ផ្តើមមុខងារបង្ហាត់ និង បង្កើតជាលក្ខណសម្រាប់ជ្រើសរើសយកនិស្សិត ស្របតាមថ្នាក់បង្ហាត់ ដែលពួកគេជ្រើសរើសរៀនជាមួយ<br>• បង្កើតជាក្រុមរួមចំណែកទាក់ទងមកលើសមធម៌ និង រាប់បញ្ចូលយោបល់បានទទួលមកវិញទៅកាន់ដំណើរការរៀបចំជាក្បួនសម្ភាស ដោយនៅពេលជាមួយគ្នា គឺរៀបចំក្បួនសម្ភាសជាខ្នាតគំរូត្រឹមត្រូវនៅតាមសាលារៀនសម្រាប់បង្ហាញជាសមធម៌ |
| **រង្វាស់ និង ឱកាសមិនស្មើ**<br>ចំណែកនៃគោលដៅ: 1, 2, & 3 | គោលដៅនៃការស្រាវជ្រាវ និង បង្កើនលទ្ធផលសម្រាប់សាលារៀន គឺស្វែងរក និង ផ្តល់អត្ថន័យអំពីសមធម៌ និង គិតគូរមើលជាគំរូសម្រាប់ប្រើសមស្របអ្វីសំខាន់មុនគេ និង បណ្តើមគំនិតមុនគេសម្រាប់សមធម៌ក្នុងក្រសួងអប់រំ ឌីស្រ្ទីគ ។ នាយកដឹកនាំសាលារៀន និង គ្រូបង្រៀននឹងធ្វើការសង្កត់យ៉ាងទៀងទាត់មកលើសមធម៌សម្រាប់ការសម្រេចបង្កើនជាកម្មវិធីអន្តរាគមន៍ និង ការបើកឱកាសផ្សេងៗសម្រាប់ជាលទ្ធផលជោគជ័យដល់សិស្ស ។ | ការិយាល័យស្រាវជ្រាវ និង បង្កើនលទ្ធផលសម្រាប់សាលារៀន | • បណ្តុះបណ្តាល និង បង្កើតជាអត្ថន័យអំពីអ្វីជាមុខងារសំខាន់មុនគេសម្រាប់ស្ទង់វាស់មកលើសមធម៌នៃក្រសួងអប់រំ LBUSD និង ផ្តល់ជាជំនួយទៅកាន់សាលារៀនសម្រាប់ប្រើតាម<br>• បង្កើតជាជាគម្រោងច្បាស់លាស់សម្រាប់ប្រើជាប្រព័ន្ធរក្សាទុកលទ្ធផលបានទទួលមកសម្រាប់ប្រើតាមជាគំរូ<br>• ប្រព្រឹត្តតាមទម្រង់ការសម្រាប់លទ្ធផលប្រមូលនៅតាមសាលារៀន ដើម្បីបង្ហាញភាពបង្កើនស្របតាមការស្នើសុំមកលើសំនួរទាក់ទងផ្នែកសមធម៌ |
| **ទំនាក់ទំនងផ្នែកពាណិជ្ជកម្ម និង ដៃគូដ៏សំខាន់**<br>ចំណែកនៃគោលដៅ: 1 & 5 | គោលដៅនៃទំនាក់ទំនងផ្នែកពាណិជ្ជកម្ម និង ដៃគូដ៏សំខាន់ គឺរក្សាជាដៃគូ និង បង្កើតជាទំនាក់ទំនងពីសិស្សប្រចាំក្រសួងអប់រំ LBUSD ទៅកាន់ពាណិជ្ជកម្ម និង ក្រសួងផ្សេងៗតាមរយៈផ្តល់ឱកាសសម្រាប់បំពេញការងាររៀនធ្វើផ្ទាល់ដៃ ។ | ការិយាល័យទំនាក់ទំនងផ្នែកពាណិជ្ជកម្ម និង ដៃគូដ៏សំខាន់ | • ផ្តល់ និង សម្របសម្រួលឱកាសស្មើគ្នាសម្រាប់ការងាររៀនធ្វើផ្ទាល់ដៃតាមរយៈបង្កើតដៃគូជាមួយក្រសួងពាណិជ្ជកម្មផ្សេងៗ<br>• បណ្តុះណ្តាល និង រៀបចំជាដៃគូថ្មីសម្រាប់ជួយសិស្សទទួលផលជោគជ័យ និង ស្របតាមបណ្តើមគំនិតនៃក្រសួងអប់រំឌីស្រ្ទីគ<br>• បង្កើតជាសមាជិកសម្រាប់ក្រុមប្រឹក្សាផ្តល់ឱវាទចម្រុះ<br>• បង្កើតជាឱកាស និង ដំណើរការសម្រាប់ទាក់ទាញចំណែកពីដៃគូពាណិជ្ជកម្មជាមួយសិស្សកម្រិតថ្នាក់ K-12 |
| **ការបង្កើនផ្នែកសិក្សា ជំនួយ និង កម្មវិធីជាបន្ថែម**<br>ចំណែកនៃគោលដៅ: 1, 3, & 5 | គោលដៅនៃការបង្កើនផ្នែកសិក្សា ជំនួយ និង កម្មវិធីជាបន្ថែម គឺធ្វើការបញ្ជាក់ថា សិស្សទាំងអស់ពិតជាបានទទួលជំនួយផ្នែកសិក្សា និង ជំនួយអប់រំផ្នែកអារម្មណ៍ និង ផ្លូវចិត្តមែនសម្រាប់សេចក្តីជោគជ័យ និង សុខុមាលភាព ។ | កម្មវិធីសិក្សាសម្រាប់កុមារភាព ការិយាល័យកម្រិតបឋមសិក្សា មធ្យមសិក្សា/K-8 និង វិទ្យាល័យ | • បណ្តុះបណ្តាលល្បឿនសិក្សា និង គម្រោងផ្តល់ជាជំនួយ និង កម្មវិធីជាបន្ថែមសម្រាប់ដោះស្រាយតាមសេចក្តីត្រូវការផ្នែកសិក្សា និង អារម្មណ៍ និង ផ្លូវចិត្តរបស់សិស្សតាមរយៈប្រើលទ្ធផលសិក្សាស្រាវជ្រាវ ដោយផ្តល់ជាកម្មវិធីអន្តរាគមន៍ កម្មវិធីបង្ហាត់ និង កម្មវិធីផ្សេងៗ កម្មវិធីពន្យល់មេរៀនអនឡាញ និង ជួបគ្នាផ្ទាល់ សាលារៀនថ្ងៃសៅរ៍ ការរៀនសងពិន្ទុឡើងវិញ និង ឱកាសផ្សេងៗសម្រាប់រៀនបន្ត (ស្របតាមគម្រោងរៀនបន្ត និង វត្តមានប្រចាំថ្ងៃ)<br>• បណ្តុះបណ្តាលជាគំរូសម្រាប់ផ្តល់កម្មវិធីអន្តរាគមន៍ផ្នែករៀនអក្សរ និង លេខចំណោទទៅកាន់សិស្សក្នុងម៉ោងកំពុងតែរៀន (កម្មវិធីរៀនអក្សរនៅតាមសាលាបឋមសិក្សា និង កម្មវិធីអន្តរាគមន៍សម្រាប់លេខចំណោទនៅតាមសាលាមធ្យមសិក្សា) |